**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧១ . សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាព នៃលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១២ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៩ ស្ដីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០ ស្ដីពីការកែសម្រួលមាត្រា ៣ នៃអនុក្រឹត្យស្ដីពីការបង្កើតលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥២ សសរ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ស្ដីពីការតែងតាំងតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពនៃលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្ដម **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | ឯកឧត្ដម គាត ឈន់ | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្ដម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤- | ឯកឧត្ដម ស៊ុន ចាន់ថុល | ទេសរដ្ឋមន្ត្រី និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥- | ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦- | ឯកឧត្តម ហ៊ឹម ឆែម | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧- | ឯកឧត្តម ប្រាក់ សុខុន | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- | ឯកឧត្តម អ៊ុន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៩- | ឯកឧត្តម នាង ផាត | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០- | ឯកឧត្តម គៅ គីមហួន | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អគ្គលេខាធិការ ។ |

**ប្រការ ២.-**

លេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជាត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនជាទៀងទាត់យ៉ាងតិច ២(ពីរ)សប្ដាហ៍ មុនរាល់កិច្ចប្រជុំកំពូលអាស៊ាន និង កិច្ចប្រជុំកំពូលពាក់ព័ន្ធ ។ ប្រធានលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជាត្រូវធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃកិច្ចប្រជុំទាំងនេះ ។

**ប្រការ ៣.-**

មុនកិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន និងក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ ប្រធានលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជាត្រូវកោះប្រជុំតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍អាស៊ាននីមួយៗ និងក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំកិច្ចប្រជុំទាំងនេះឱ្យបានល្អ ។

**ប្រការ ៤.-**

ប្រធានលេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជាអាចអញ្ជើញប្រធានស្ថាប័នពាក់ព័ន្ធមកប្រជុំ ក្នុងករណីចាំបាច់ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ